JobAccess
Driving disability employment

# បណ្ណព័ត៌មាន

## តើអ្នកជាជនវ័យក្មេងដែលមានពិការភាពហើយកំពុងស្វែងរកការងារធ្វើឬ?

មានសេវាផ្សេងៗដោយឥតគិតថ្លៃដែលអាចជួយអ្នកនៅខណៈដែលអ្នកកំពុងបញ្ចប់ការសិក្សា វគ្គបណ្តុះបណ្តាល ឬការសិក្សាថ្នាក់កំរិតឧត្តម និងឈានទៅធ្វើការ ។ សេវាទាំងនេះមានរួមទាំង ៖

**សេវាការងារសម្រាប់ជនពិការ** (Disability Employment Services) (DES)

សេវាការងារសម្រាប់ជនពិការ ជួយដល់បណ្តាប្រជាជនវ័យក្មេងដែលមានសិទ្ធិទទួល  ដោយសារមានពិការភាព របួស ឬលក្ខណៈសុខភាព ក្នុងការស្វែងរក និងរក្សារការងារ ។

**កម្មវិធីអភិវឌ្ឍសហគមន៍**

**កម្មវិធីអភិវឌ្ឍសហគមន៍** (Community Development Programme) (CDP)

**អាចជួយអ្នកប្រសិនជាអ្នករស់នៅតំបន់ដាច់ស្រយាលក្នុងប្រទេសអូស្ត្រាលី នឹងកំពុងស្វែងរកការងារធ្វើ។**

**ដំណាក់កាលឈានទៅធ្វើការ** (Transition to Work) (TTW)

ប្រសិនជាអ្នកមានអាយុរវាង 15  និង 21 ឆ្នាំ អ្នកអាចទទួលបានជំនួយតាមរយៈ TTW ។ TTW អាចជួយអ្នកត្រៀមខ្លួនសំរាប់ការងារតាមរយៈការបណ្តុះបណ្តាលស្តីពីអាកប្បកិរិយានៅទីកន្លែងការងារ និងការរំពឹងទុកនានានៅទីកន្លែងការងារ  ព្រមទាំងការអភិវឌ្ឍជំនាញផ្សេងៗសំរាប់ការងារ និងការសិក្សា ។

**មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ** (Vocational, Training & Employment Centres) (VTECs)

Australian Government

JobAccess is the national hub for workplace and employment information for people with disability, employers and service providers.

**1800 464 800** **www.jobaccess.gov.au**

**បើអ្នកជាអ្នកស្វែងរកការងារវ័យក្មេង និងជាមនុស្សជនជាតិដើមនៃប្រទេសអូស្ត្រាលី** (Indigenous) **មានពិការភាព និងកំពុងស្វែងរកការងារធ្វើ នោះ** VTECs **អាចជួយអ្នកបាន ។**

## កម្មវិធីហ្វឹកហ្វឺនជំនាញការងារ និងកម្មវិធីបង្ហាត់បង្រៀនធ្វើការ

**អ្នកអាចចាប់អារម្មណ៍និងកម្មវិធីហ្វឹកហ្វឺនជំនាញការងារ ឬក៏កម្មវិធីបង្ហាត់បង្រៀនធ្វើការ ដែលជាវិធីមួយក្នុងការទទួលបានសញ្ញាបត្រការងារ និងការងារធ្វើតែម្តង ។**

**បើលោកអ្នកចង់បានព័ត៌មានបន្ថែមស្តីអំពីសេវាទាំងនេះ លោកអ្នកអាចមើលទំព័រ** JobAccess **នៅ** www.jobaccess.gov.au **ឬក៏ទាក់ទងមកអ្នកផ្តល់យោបល់របស់** JobAccess **តាមរយៈលេខ** 1800 464 800 – **ការទាក់ទងតាមទូរសព្ទ័ដែត្រូវគេគិតថ្លៃ។**